ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ

Pre-Trial Chamber
Chambre Préliminaire

ឯកសារ D381/41 & D382/40

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦១)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-Mar-2021, 16:00
CMS/CFO: Sann Rada

---

សាធារណៈ

## សេចក្តីសម្រេចលើសវនាការផ្ទាល់មាត់នៅក្នុងសំណុំរឿង ០០៤

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Brenda J. HOLLIS

**សហមេធាវីការពារក្តី យឹម ទិត្យ:**

សូ មូស្សេទ្ធី
Susana TOMANOVIC

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

ស៊ិន សុវ៉ន

ទី ស្រ៊ីនណា

វ៉ែន ពៅ

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួលសេចក្តីសន្និដ្ឋានរបស់ភាគីពាក់ព័ន្ធនឹងសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤[1]។

## I. សាវតារនីតិវិធី និងសេចក្តីសន្និដ្ឋាន

1. នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានអញ្ជើញភាគីនៃសំណុំរឿង ០០៤ តាមរយៈអ៊ីមែល ឲ្យដាក់សេចក្តីសន្និដ្ឋានលើករណីថា តើអង្គបុរេជំនុំជម្រះគួររៀបចំសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤ ដែរឬយ៉ាងណា។ ភាគីត្រូវបានណែនាំឲ្យដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងរយៈពេល ០៣ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីអ៊ីមែលនេះ[2]។

2. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួន[3] ដោយបានស្នើសុំឲ្យមានសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤[4] ឬបើមិនដូច្នោះទេ ភាគីអាចដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរអំពីខ្លឹមសារនៃសេចក្តីសម្រេចរបស់

---

[1] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស (“សំណុំរឿង ០០៤”) សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (យឹម ទិត្យ) ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/36 & D382/35 (“សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/36 & D382/35)”)។ សំណុំរឿង ០០៤ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាជាតិពាក់ព័ន្ធនឹងសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ៊ីមែល ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/40 & D382/39។ សំណុំរឿង ០០៤ សារណារបស់ យឹម ទិត្យ ជូនអង្គបុរេជំនុំជម្រះស្តីពីភាពចាំបាច់សម្រាប់សវនាការផ្ទាល់មាត់ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/38 & D382/37 (“សារណារបស់ យឹម ទិត្យ (ឯកសារ D381/38 & D382/37)”)។ សំណុំរឿង ០០៤ ការយល់ឃើញរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើសវនាការផ្ទាល់មាត់ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ ឯកសារ D381/39 & D382/38 (“ការយល់ឃើញរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/39 & D382/38)”)។

[2] សំណុំរឿង ០០៤ សេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះជូនដល់ភាគី អ៊ីមែល ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។

[3] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/36 & D382/35)។

[4] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/36 & D382/35) កថាខណ្ឌ ១។

អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០៤/០២ នៅត្រង់ផ្នែកសេចក្ដីសម្រេចនៃសំណុំរឿង ០០៤[5]។

3. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (“សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី”) តាមរយៈអ៊ីមែល បានស្នើសុំពន្យារពេលដាក់សេចក្ដីសន្និដ្ឋានរយៈពេល ០១ ថ្ងៃបន្ថែម ដោយសារគណនី អ.វ.ត.ក មួយចំនួន ត្រូវបានផ្ដាច់ និងដោយសារពេលវេលាខុសគ្នារវាងសហមេធាវី[6]។ នៅថ្ងៃដដែលនោះ អង្គបុរេជំនុំជម្រះ តាមរយៈអ៊ីមែល បានយល់ព្រមតាមសំណើសុំរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងបានពន្យារកាលបរិច្ឆេទដាក់សេចក្ដីសន្និដ្ឋានរយៈពេល ០១ ថ្ងៃបន្ថែម[7]។

4. នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាជាតិ តាមរយៈអ៊ីមែល បានធ្វើសេចក្ដីសន្និដ្ឋានថា អនុលោមតាមវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចសម្រេចបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគី ឬ អាចសម្រេចរៀបចំសវនាការផ្ទាល់មាត់។ សហព្រះរាជអាជ្ញាជាតិ បានទុកជូនអង្គបុរេជំនុំជម្រះធ្វើសេចក្ដីសម្រេចលើករណីនេះ[8]។

---

5 សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/36 & D382/35) កថាខណ្ឌ ៤ *យោងលើ* សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/អជសង-អជតក សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2។

6 សំណុំរឿង ០០៤ សំណើសុំពន្យារពេលដាក់សេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងសវនាការផ្ទាល់មាត់លើសំណុំរឿង ០០៤ អ៊ីមែល ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១។

7 សំណុំរឿង ០០៤ ចម្លើយតបទៅនឹងសំណើសុំពន្យារពេលដាក់សេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងសវនាការផ្ទាល់មាត់លើសំណុំរឿង ០០៤ អ៊ីមែល ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១។

8 សំណុំរឿង ០០៤ សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាជាតិពាក់ព័ន្ធនឹងសវនាការផ្ទាល់មាត់លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ៊ីមែលចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/40 & D382/39។

5. នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ សហមេធាវី យ៉ឹម ទិត្យ ("សហមេធាវី") បានដាក់សារណា របស់ខ្លួន ដោយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះកំណត់កាលបរិច្ឆេទសវនាការផ្ទាល់មាត់នៅក្នុងសំណុំរឿង ០០៤"[9]។

6. នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ការយល់ឃើញរបស់ខ្លួន[10] ដោយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (i) កំណត់កាលបរិច្ឆេទសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (ii) ផ្តល់សេចក្តីជូនដំណឹងក្នុងពេលវេលាសមស្របអំពីកាលបរិច្ឆេទសវនាការ និង (iii) ផ្តល់មធ្យោបាយចូលរួមដល់មេធាវីតាមរយៈប្រព័ន្ធវីដេអូ និង (iv) បង្គាប់ឱ្យមានការប្រុងប្រយ័ត្នឱ្យបានសមស្របជាមុនដើម្បីកាត់បន្ថយហានិយភ័យនៃការចម្លងជំងឺកូវីដ-១៩ តាមរយៈការចូលរួមសវនាការ[11]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានរក្សាសិទ្ធិមិនចូលរួមនៅក្នុងសវនាការផ្ទាល់មាត់ ដោយសារស្ថានភាពនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា[12]។

## II. អង្គសេចក្តី

7. អង្គបុរេជំនុំជម្រះសូមរំលឹកឡើងវិញអំពីឆន្ទានុសិទ្ធិទូលំទូលាយ អនុលោមតាមវិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុង ក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។ ក្រោយពីបានពិចារណាត្រឹមត្រូវលើការយល់ឃើញរបស់ភាគី[13] អង្គបុរេជំនុំជម្រះសម្រេចបន្តធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា

---

[9] សារណារបស់ យ៉ឹម ទិត្យ (ឯកសារ D381/38 & D382/37)។

[10] ការយល់ឃើញរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/39 & D382/38)។

[11] ការយល់ឃើញរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/39 & D382/38) កថាខណ្ឌ១-២, ១៨។

[12] ការយល់ឃើញរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/39 & D382/38) កថាខណ្ឌ១៦។

[13] ចំពោះទឡ្ហីករណ៍របស់ភាគីពាក់ព័ន្ធនឹងលក្ខណៈសាធារណៈ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសង្កេតឃើញថា ក្រៅពីបញ្ហាចោទមួយចំនួនដែលក្រុមប្រឹក្សាជំនុំជម្រះបានលើកឡើង ទឡ្ហីករណ៍ផ្ទាល់មាត់ដែលបានលើកឡើងនៅក្នុងអំឡុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/១ សំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣ ត្រូវបានកម្រិតត្រឹមសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគី និងបានរៀបចំសវនាការជា*អសាធារណៈ* (លើកលែងតែពេលចាប់ផ្តើម និងការអានរបាយការណ៍សំណុំរឿងជាសាធារណៈតែប៉ុណ្ណោះ)។ សេចក្តីសន្និដ្ឋានរបស់ភាគីលើបណ្តឹងឧទ្ធរណ៍នានានៅក្នុងសំណុំរឿង ០០៤ នឹងត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញជាឯកសារសាធារណៈនៅក្នុងពេលពាក់ព័ន្ធណាមួយ។

*សេចក្តីសម្រេចលើសវនាការផ្ទាល់មាត់នៅក្នុងសំណុំរឿង ០០៤*

ដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។

8. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា អង្គបុរេជំនុំជម្រះកំពុងពិនិត្យសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សេចក្តីសន្និដ្ឋានបន្ថែមលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ប្រឆាំង យឹម ទិត្យ នៅឡើយ[14]។

## III. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

បន្តសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។

អនុលោមតាមវិធាន ៧៧(១៣) សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

អនុលោមតាមវិធាន ៧៧(១៣)(គ) សេចក្តីសម្រេចនេះត្រូវជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេត និងភាគី តាមរយៈក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ។

**រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៉ី ធុល** **Kang Jin BAIK** **ហួត វុទ្ធី**

---

[14] សំណុំរឿង ០០៤ សំណើ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ ឯកសារ D381/29។ *សូមមើលបន្ថែម* សំណុំរឿង ០០៤ ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញអន្តរជាតិសុំដាក់សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ឯកសារ D381/31។